មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0014**

សម្ភាសន៍ជាមួយឈ្មោះ អ៊ូច សារឿន ភេទស្រី អាយុ៥៩ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម“ចុងភៅ”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិពោធិ៍២ដើម ឃុំវាលរហាត់ ស្រុកមង្គលបូរី ខេត្តបាត់ដំបង

រស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៤០:៥៦

២១ទំព័រ

ប៊ុនថនៈ ខ្ញុំសូមអនុញ្ញាតិសម្ភាសន៍អ៊ី?

សារឿនៈ ចាស ។

ប៊ុនថនៈ ជាដំបូងខ្ញុំចង់សួរឈ្មោះអ៊ី អ៊ីឈ្មោះអីដែរ?

សារឿនៈ ឈ្មោះ អ៊ូច សារឿន ។

ប៊ុនថនៈ អ៊ីអាយុប៉ុន្មានហើយ?

សារឿនៈ សព្វថ្ងៃនេះអាយុ៥៩ ។

ប៊ុនថនៈ អ៊ីមានស្រុកកំណើតនៅណាដែរ?

សារឿនៈ ស្រុកកំណើតនៅឃុំរហាត់ទឹក ។

ប៊ុនថនៈ ចឹងភូមិអីដែរ?

សារឿនៈ ភូមិពោធិពីរដើម ។

ប៊ុនថនៈ ភូមិពោធិពីរដើម?

សារឿនៈ ចាស ។

ប៊ុនថនៈ ចឹងឃុំរហាត់លទឹក?

សារឿនៈ ចាស ។

ប៊ុនថនៈ ស្រុកមង្គលបូរី?

សារឿនៈ ស្រុកមង្គលបូរី ។

ប៊ុនថនៈ ខេត្តបន្ទាយមានជ័យ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

សារឿនៈ ចាស ។

ប៊ុនថនៈ ចឹងសព្វថ្ងៃនេះនៅអ៊ីរស់នៅក្នុងភូមិឃុំអីដែរ?

សារឿនៈ ភូមិត្រសេកជ្រុំ ។

ប៊ុនថនៈ ឃុំម៉ាឡៃ?

សារឿនៈ ចាស ។

ប៊ុនថនៈ អ៊ីមានកូនប៉ុន្មាននាក់?

សារឿនៈ កូនទាំងអស់៧នាក់ មានប្តីមានប្រពន្ធអស់ហើយនៅសល់តែម្នាក់ ។

ប៊ុនថនៈ ម្នាក់ហ្នឹងនៅជាមួយអ៊ី?

សារឿនៈ ចាស ។

ប៊ុនថនៈ ចឹងពីដើមអ៊ីមានបងប្អូនប៉ុន្មាននាក់?

សារឿនៈ បងប្អូនមាន៧នាក់ ។

ប៊ុនថនៈ បងប្អូនមាន៧នាក់ដែរ?

សារឿនៈ ចាស!មកឃុំរហាត់ទឹកទាំងអស់គ្នា ។

ប៊ុនថនៈ ចឹងអ៊ីកូនប៉ុន្មាន?

សារឿនៈ កូនទី១ ។

ប៊ុនថនៈ មានប្រុសប៉ុន្មានស្រីប៉ុន្មានដែរ?

សារឿនៈ ស្រីទាំង៧ ។

ប៊ុនថនៈ ស្រី៧នាក់?

សារឿនៈ ចាស!អត់មានប្រុសទេ ម៉ែខ្ញុំមានស្រីទាំង៧ ។

ប៊ុនថនៈ ចឹងរាល់ថ្ងៃគាត់នៅរស់ដែលឪពុកម្តាយ?

សារឿនៈ នៅតែម៉ែអាយុជិត១០០ហើយ ឪពុកខូចនៅតែម៉ែ ។

ប៊ុនថនៈ ឪពុកអ៊ីខូចនៅឆ្នាំណា?

សារឿនៈ គាត់ខូចយូរគ្រាន់ដែលហើយ មិនដឹងជាឆ្នាំណាទេ តែគាត់ខូចយូរដែរ គាត់ខូចជាងម្ភៃហើយគាត់ខូច ។

ប៊ុនថនៈ ជាងម្ភៃឆ្នាំហើយគាត់ខូចតាំងពី៩០?

សារឿនៈ ចាស!តាំងពីយួនចូលនោះ យួនចូលមកនៅក្នុងតាមភូមិ ។

ប៊ុនថនៈ បាទ ។

សារឿនៈ គាត់ខូច ។

ប៊ុនថន៖ ចឹងគាត់ខូចដោយសារអីដែលគាត់ឈឺប៉ុយ៉ាងម៉េច?

សារឿន៖ គាត់ឈឺដោយជំងឺខ្លួនគាត់ ។

ប៊ុនថន៖ បាទ ។

សារឿន៖ កាលសម័យប៉ុល ពតគេឲ្យគាត់ធ្វើចំការធ្វើអីទៅ គាត់ចេះតែមិនស្រួលគ្រាំៗគាត់ ។

ប៊ុនថន៖ ចឹងម្តាយនៅរាល់ថ្ងៃហ្នឹងគាត់ដើរបានទេ?

សារឿន៖ ដើរបានគាត់នៅតែវត្ត កូនចៅយកនៅជាមួយអត់នៅសោះគាត់នៅតែវត្ត ។

ប៊ុនថន៖ គាត់អត់ចេះនៅ?

សារឿន៖ ឈឺយ៉ាងណាក៏ដោយយកគាត់មកផ្ទះគាត់អត់មកទេ ។

ប៊ុនថន៖ បាទ ។

សារឿន៖ គាត់សុខចិត្តនៅតែក្នុងវត្ត កូនចៅយកអីទៅ គាត់ឈឺនៅមើលគាត់ទៅ ។

ប៊ុនថន៖ តែគាត់ដើរបានហូបបានធម្មតា?

សារឿន៖ គាត់ដើរបានគាត់ហូបបានតែគាត់បំរើលោកដាំបាយទឹកក្តៅទឹកត្រជាក់បំរើលោករាល់ថ្ងៃ គាត់ជិត១០០ហើយតែគាត់មាំ ។

ប៊ុនថន៖ ៩០ប៉ុន្មានហើយអាយុគាត់?

សារឿន៖ គាត់ចៅច្រើនណាស់ ចៅលួតចៅលាម៉ាចប់ គាត់មានម៉ាចប់ចៅ ។

ប៊ុនថន៖ តែអាយុ៩០ប៉ុន្មាន?

សារឿន៖ គាត់៩៨ហើយ សល់តែ២ឆ្នាំទៀតទេគាត់១០០ហើយ ។

ប៊ុនថន៖ ចឹងគាត់នៅដើរបាន?

សារឿន៖ ដើរបាន ។

ប៊ុនថន៖ ចឹងអ៊ំកាលពីនៅតូចហ្នឹងមានបានរៀនសូត្រអីទេ?

សារឿន៖ រៀនដែលតែខ្ញុំរៀនមិនបានជ្រៅជ្រះអីទេ ។

ប៊ុនថន៖ បាទ ។

សារឿន៖ រៀនទៅលែងតែម៉ែឪក្រដល់សម័យប៉ុល ពតរៀនអក្ខរកម្មទៅភ្លេចភ្លាំងអស់ទៅវិញទៅ រាល់ថ្ងៃមិនចេះអក្សរទេ ។

ប៊ុនថន៖ បាទ ។

សារឿន៖ គ្រាន់តែមើលឈ្មោះអីដាច់ ។

ប៊ុនថន៖ ចឹងមើលបានតិចៗអ៊ឺ?

សារឿន៖ ចាស ។

ប៊ុនថន៖	អ៊ីអាយុ៨៩ហ្នឹងកើតឆ្នាំណា?

សារឿន៖	មិនដឹងជាឆ្នាំណាទេ ដាក់ក្នុងសៀវភៅ ។

ប៊ុនថន៖	ឆ្នាំ៦០ជាង?

សារឿន៖	មែនដឹង ។

ប៊ុនថន៖	ជំនាន់សម្តេច?

សារឿន៖	ចាស!ជំនាន់សម្តេចឪហ្នឹង ។

ប៊ុនថន៖	ចឹងអ៊ីនៅក្នុងភូមិហ្នឹងបន្ទាប់ពីឈប់រៀន អ៊ីទៅធ្វើអី?

សារឿន៖	កាលហ្នឹងដើរធ្វើកម្មករអីគេទៅ ធ្វើស្រែចំការអីគេទៅ ។

ប៊ុនថន៖	ស្រែចំការឪពុកម្តាយអ៊ី?

សារឿន៖	ចាស ។

ប៊ុនថន៖	កាលហ្នឹងគាត់ធ្វើច្រើនទេ ស្រែ?

សារឿន៖	អត់ទេ មិនមានច្រើនទេ ចែកកូនម្នាក់តិចៗគាត់ចាស់ហើយក៏អត់ទៅ ។

ប៊ុនថន៖	និយាយពីជំនាន់មុនណាអ៊ី?

សារឿន៖	ចាស!កាលជំនាន់មុនមានបន្តិចបន្តួច ។

ប៊ុនថន៖	បាទ ។

សារឿន៖	ស្រែចំការម៉ែចែកបន្តិចៗមកយើងចែកតៗកូនទៅក៏អស់ទាំងអស់គ្នាទៅវិញទៅ ។

ប៊ុនថន៖	បាទ ។

សារឿន៖	ខ្ញុំក្រហ្នឹងខ្មោចឪប្តីខ្ញុំឈឺក៏លក់ស្រែអស់វិញ គាត់ឈឺខូចទៅ ។

ប៊ុនថន៖	អ៊ីចង់ឲ្យអ៊ីរៀបរាប់កាលដែលអ៊ីនៅជាមួយឪពុកម្តាយណាស់អ៊ី កាលនៅពីក្មេងអ៊ីបានចូលរៀនហើយបន្ទាប់មកអ៊ីឈប់រៀន?

សារឿន៖	ចាស ។

ប៊ុនថន៖	រៀនបានប៉ុន្មានឆ្នាំបានអ៊ីឈប់រៀនអ៊ី?

សារឿន៖	ចាស!ឈប់រៀន ។

ប៊ុនថន៖	រៀនបានប៉ុន្មានឆ្នាំបានឈប់រៀន?

សារឿន៖	រៀនតែពីតូចៗហ្នឹងមក ឈប់រៀនទៅនៅបំរើម៉ែឪហ្នឹង ។

ប៊ុនថន៖	បាទ ។

សារឿន៖	ធ្វើការធ្វើអីបំរើម្តាយ ។

ប៊ុនថន៖	ធ្វើការអីខ្លះ?

សារឿនៈ ស៊ីឈ្នួលច្រូតស្រូវគេទៅបងប្អូនសុទ្ធតែស្រីៗ ។

ប៊ុនថនៈ ចឹងប្អូនៗមានបានទៅរៀនទេ?

សារឿនៈ ប្អូនៗបានរៀនខ្លះដែរ ប្អូនរៀនខ្លះអត់ខ្លះ ចេះខ្លះមិនចេះខ្លះពីសម័យហ្នឹងម៉ែឪខ្ញុំក្រណាស់ក្រនោះ ។

ប៊ុនថនៈ គាត់ធ្វើតែស្រែ?

សារឿនៈ គាត់អត់ទេ ធ្វើស្រែទៅគាត់រកត្រីរកសាច់អីទៅ ពុកខ្ញុំនៅពីក្មេងគាត់រកត្រីអីហ្នឹង ។

ប៊ុនថនៈ បាទ ។

សារឿនៈ លក់ដូរទៅលក់អានេះលក់អានោះលក់ដូរទៅ ចិញ្ចឹមប្អូនចិញ្ចឹមម៉ែ ។

ប៊ុនថនៈ ចឹងមីងកូនច្បង?

សារឿនៈ ចាស ។

ប៊ុនថនៈ ចឹងកាលសម័យលន់ នល់ហ្នឹងអ៊ីឈប់រៀនហើយ?

សារឿនៈ ចាស ។

ប៊ុនថនៈ ឈប់រៀនហើយនៅក្នុងភូមិហ្នឹងមានចូលកងអីទេ?

សារឿនៈ អត់ទេ អត់មានបានចូលកងហ្នឹងគេជងកាលហ្នឹង ខ្ញុំឈប់រៀនរហូត ។

ប៊ុនថនៈ ចឹងកាលឆ្នាំ៧៥នៅពេលរំដោះ?

សារឿនៈ ឆ្នាំ៧៥ខ្ញុំបានកូនបីនាក់ ។

ប៊ុនថនៈ ចឹងអ៊ីរៀបការនៅឆ្នាំណា?

សារឿនៈ ខ្ញុំឆ្នាំណាចេះខ្ញុំអត់ចាំផង ខ្ញុំការតាំងពីអាយុខ្ញុំ១៤ ។

ប៊ុនថនៈ ការអាយុ១៤?

សារឿនៈ ចាស!ការអាយុ១៤ រហូតដល់៥៩ ។

ប៊ុនថនៈ ឆ្នាំ៧៥ឆ្នាំបែក?

សារឿនៈ ឆ្នាំរត់ហ្នឹងឯង ។

ប៊ុនថនៈ ឆ្នាំរត់ហ្នឹងអ៊ីបានកូនប៉ុន្មានហើយ?

សារឿនៈ កូន៣ ។

ប៊ុនថនៈ អ៊ីរត់ទៅណា?

សារឿនៈ រត់នៅមង្គលបូរី ចុះនៅតាមអូរអីចេះតែពួនក្រឡុកក្រលៀតទំរាំបានចូលមកក្នុងភូមិវិញ ។

ប៊ុនថនៈ ចឹងកាលរត់ទៅហ្នឹងរត់ទៅទាំងគ្រួសារឪពុកម្តាយ?

សារឿនៈ ចាស!រត់ទៅទាំងអស់ទាំងឪពុកម្តាយទាំងប្តី ទាំងម៉ែទាំងកូនអីទាំងអស់ ។

ប៊ុនថន៖ នៅភូមិណាដែរ?

សារឿន៖ កាលហ្នឹងគេចុះទៅនៅខាងក្រោយអី មិនដាស្អីដឹងថាមគ្គុលបូរីចុះទៅក្រោយទៅពួននៅកៀនៗហ្នឹងទៅ។

ប៊ុនថន៖ យ៉ាងម៉េចបានរត់ កាលហ្នឹង?

សារឿន៖ កាលឆ្នាំ៧៥ហ្នឹងមានពួកខ្មែរក្រហមចូលមក។

ប៊ុនថន៖ បាទ។

សារឿន៖ ឲ្យយើងរត់ចេញពីភូមិសិនទៅ ស្ងាត់ក៏ចូលវិញទៅ។

ប៊ុនថន៖ ចឹងក្រៅពីគ្រួសារអ៊ីមានអ្នកផ្សេងរត់ទៅជាមួយទេ?

សារឿន៖ ទៅអស់មួយភូមិៗហ្នឹង រត់ទៅទាំងអស់ៗចាស ចូលទៅវិញចូលទៅទាំងអស់វិញ។

ប៊ុនថន៖ ចឹងរត់ទៅនៅក្រៅភូមិហ្នឹងរយៈពេលប៉ុន្មានបានរត់ចូលភូមិវិញ?

សារឿន៖ កាលជំនាន់ហ្នឹងមិនបានមួយខែអី ស្ងាត់ចូលមកវិញ។

ប៊ុនថន៖ ចឹងនិយាយថាចូលទៅរស់នៅធម្មតាទេ?

សារឿន៖ ចាស។

ប៊ុនថន៖ ហើយខ្មែរក្រហមនៅក្នុងភូមិហ្នឹង?

សារឿន៖ ចាស។

ប៊ុនថន៖ អ៊ីមានធ្វើការងារអីទេ កាលហ្នឹង?

សារឿន៖ ជំនាន់ខ្មែរក្រហមខ្ញុំអត់ទេ ដូចថាគេចាត់ចែកទៅខ្ញុំអ្នកលាងចាន។

ប៊ុនថន៖ លាងចាន?

សារឿន៖ ចាស!លាងចានកិនស្រូវអីទៅ ធ្វើអង្ករឲ្យគេហូបបំរើគេចានឆ្នាំងយើងកូនតូច។

ប៊ុនថន៖ បាទ!កាលហ្នឹងមីងមានកូនខ្ចីទៀត?

សារឿន៖ ចាស!កូនខ្ចី។

ប៊ុនថន៖ ហើយគ្រួសារអ៊ី?

សារឿន៖ គ្រួសារខ្ញុំរកត្រី ចពញ្ចឹមគេទាំងអស់។

ប៊ុនថន៖ ចឹងនៅខាងរោងបាយ?

សារឿន៖ ចាស!ធ្វើនេសាទត្រី។

ប៊ុនថន៖ ចុះឪពុកម្ដាយ?

សារឿន៖ ម៉ែខ្ញុំខាងចុងភៅ។

ប៊ុនថន៖ ចុងភៅដែរ?

សារឿនៈ ចាស ។

ប៊ុនថនៈ ចុះឪពុក?

សារឿនៈ ឪពុកខ្ញុំគេឲ្យឃ្វាលគោ គេដកពិសោធន៍ ឪពុកខ្ញុំគាត់ធ្វើជាប៉ូលីស ។

ប៊ុនថនៈ អូ!គាត់ធ្វើប៉ូលីសផង?

សារឿនៈ ចាស!ធ្វើប៉ូលីសខ្ញុំភ័យ គេចង់សម្លាប់ពុកខ្ញុំតែបានមកប្អូនខាងម៉ែខ្ញុំបានធ្វើយោធាអីខ្វះចឹង ទៅណាស់ ។

ប៊ុនថនៈ គេជួយលាក់?

សារឿនៈ គេមិនជួយលាក់អីទេ តែគេមិនបានរករឿងរកអី តែគេមិនស្រាវជ្រាវយើងតែចេះតែ ភ័យដែរ ។

ប៊ុនថនៈ បាទ ។

សារឿនៈ តែគាត់គេឲ្យឃ្វាលគោជាមួយកុមារៗ ខ្ញុំគេឲ្យលាងចានលាងអី ។

ប៊ុនថនៈ ចឹងប្អូនអ៊ីនោះ?

សារឿនៈ ប្អូនៗខ្ញុំនៅសមរភូមិមុខ គេប្រើទៅដកស្ទូងអីទៅច្រូតកាត់ ។

ប៊ុនថនៈ ចឹងអ៊ឹមាននៅជុំគ្រួសារទេ?

សារឿនៈ ចាស!ជុំ កាលហ្នឹងគេជម្លៀសមកនៅខាងភូមិលាវតែជម្លៀសទាំងអស់ម៉ាគ្រួសារបងប្អូន ខ្ញុំហ្នឹងនៅជុំគ្នាដដែល ។

ប៊ុនថនៈ ចឹងចូលភូមិហើយបានគេជម្លៀសទៅភូមិលាវទៀត?

សារឿនៈ ចូលដំបូងខ្ញុំនៅខាអូរម្ទេសស៊ីងម្នាក់ ខាងនេះភូមិពោធិពីរដើមហ្នឹង ។

ប៊ុនថនៈ បាទ ។

សារឿនៈ ខាងនេះខ្មែរខាងនោះលាវ ដល់គេជម្លៀសចេញទៅខាងភូមិលាវទាំងអស់ជុំគ្នា ។

ប៊ុនថនៈ បាទ ។

សារឿនៈ ផ្ទះសំបែងខ្ញុំគេរើទៅ គេរើអស់ផ្ទះខ្មែរៗគេរើធ្វើសហករណ៍អស់ ទៅនៅផ្ទះលាវ ។

ប៊ុនថនៈ ចឹងខាងលាវទៅនៅណា?

សារឿនៈ លាវនៅជុំគ្នាទាំងអស់ យើងទៅនៅជុំលាងទាំងអស់ ផ្ទះណាធំទៅគេដាក់ពីរបីគ្រួសារ ។

ប៊ុនថនៈ បាទ ។

សារឿនៈ ផ្ទះមួយគេដាក់ពីរបីគ្រួសារទាំងខ្មែរទាំងលាវទាំងអស់គ្នាទៅ ។

ប៊ុនថនៈ បាទ ។

សារឿនៈ ដល់បានសន្តិភាពមកខ្ញុំមកនៅដីឯងវិញទេ កាប់ឫស្សីអីធ្វើខ្ទមទៅធ្វើផ្ទះនៅរៀងៗខ្លួនវិញ

ន្ទាប់ពីគេរើរុះទៅក៏អស់ទៅ ។

ប៊ុនថន៖ បាទ ។

សារឿន៖ យើងម្ចាស់ផ្ទះក៏អត់ ។

ប៊ុនថន៖ ចឹងកាលហ្នឹងម្ហូបអាហារអីអ៊ីហូបគ្រប់គ្រាន់ទេ?

សារឿន៖ កាលសម័យប៉ុល ពត?

ប៊ុនថន៖ បាទ ។

សារឿន៖ កាលហ្នឹងកាលណាទៅក៏បបរខ្វះទៅ មានបាយបបរ ។

ប៊ុនថន៖ ចឹងកាលហ្នឹងបានហូបឆ្អែតទេ?

សារឿន៖ បានហូបឆ្អែតអត់អី សហករណ៍កន្លែងខ្ញុំធ្វើស្រែបាន ។

ប៊ុនថន៖ កាលហ្នឹងគេហៅសហករណ៍អីវិញ?

សារឿន៖ កាលហ្នឹងគេហៅសហករណ៍ដើមពោធិពីរដើមចឹងឯង ។

ប៊ុនថន៖ ចឹងអ៊ីចេញពីសហករណ៍ពីដើមហ្នឹងទៅនៅភូមិលាវហើយ?

សារឿន៖ ភូមិលាវក៏ពោធិពីរដើមដូចគ្នា ភូមិទាំងអស់គ្នានៅហ្នឹង ។

ប៊ុនថន៖ តែយ៉ាងម៉េចបានគេហៅភូមិលាវហ្នឹង?

សារឿន៖ ចុះខាងនោះលាវ ពួកលាវម៉ាចំហៀងខ្មែរម៉ាចំហៀងនៅតាំងពីអើយសព្វថ្ងៃគេនៅចឹងដូចតែគ្នា ។

ប៊ុនថន៖ ចឹងសព្វថ្ងៃគេមានបែងចែកដាច់ហើយនៅ?

សារឿន៖ លាវនៅដីលាវអាអូន ។

ប៊ុនថន៖ គេហៅភូមិលាវតែម្ដង?

សារឿន៖ ចាស! ខ្មែរហ្នឹងនៅខាងខ្មែរហ្នឹងទៅឆ្លងស៊ីងគ្នាទៅមក ។

ប៊ុនថន៖ ចឹងក្រៅពីធ្វើការលោងចានអ៊ីមានធ្វើការអីទៀតទេ?

សារឿន៖ អត់ទេ លាងចានរហូតចឹងមកច្រូត ឲ្យទៅច្រូតស្រូវនៅសមរភូមិមុខ កាលដែលយើងមិនកើតកូន ។

ប៊ុនថន៖ បាទ ។

សារឿន៖ ចាស!ទៅច្រូតស្រូវរួចគេឲ្យយើងលាងចានលាងអីលាងចានលាងអីសរសៃខ្ចីនោះដល់នេះទៅបានពួកយួនអីចូលមកសន្តិភាព ។

ប៊ុនថន៖ ចឹងអ៊ីមានជម្លៀសទៅណា?

សារឿន៖ អត់ទេ!អត់មានបានជម្លៀសចេញពីភូមិទេ ចេញពីភូមិហ្នឹងទៅនៅភូមិដដែលជាមួយលាវ

ប៉ុណ្ណឹងឯង ភូមិជុំតែគ្នាខាងស្ទឹងម្នាក់ ។

ប៊ុនថនៈ ចឹងគ្រួសារអ៊ីមានជម្រៀសទៅណាផ្សេងទេ?

សារឿនៈ អត់មានទៅណាទេ គេឲ្យគាត់រកត្រីគាត់រកតែត្រីគាត់ស្ទូតណាស់ ។

ប៊ុនថនៈ បាទ ។

សារឿនៈ គាត់រកតែត្រីហ្នឹង ។

ប៊ុនថនៈ ចុះឥឡូវគាត់នៅរស់ទេ?

សារឿនៈ ខូចហើយ គាត់តាំងពីកូនខ្ញុំនៅពោះសព្វថ្ងៃអាយុ៦ឆ្នាំ ឥឡូវនេះកូនពៅខ្ញុំអាយុ២១ ។

ប៊ុនថនៈ ២១?

សារឿនៈ ចាស ។

ប៊ុនថនៈ ចឹងសម័យហ្នឹងបងប្អូននៅជុំគ្នាទាំងអស់អត់មានខូចទេ?

សារឿនៈ ចាស!អត់មានទេ ។

ប៊ុនថនៈ ចឹងជុំគ្នាទាំងអស់ ។

សារឿនៈ ចាស ។

ប៊ុនថនៈ ចឹងនិយាយថាការគ្រប់គ្រងអីមានលក្ខណៈតឹងតែងទេ?

សារឿនៈ ខ្លះមកក៏តឹងបន្តិចទៅខ្លះមកក៏គ្រាន់តិចទៅ ផ្លាស់ពីរបីផ្នែកទៅ ។

ប៊ុនថនៈ បាទ!គេមកពីខាងណាវិញអ្នកគ្រប់គ្រងអ្នកគ្រប់គ្រងដូចជារោងបាយអីអីហ្នឹង?

សារឿនៈ ពួកខាងណាណីទេ គេហៅពួកស្អីទេមិនសូវចាំផង ពួកនិរតីពួកអី ។

ប៊ុនថនៈ ខាងនិរតី?

សារឿនៈ ចាស ។

ប៊ុនថនៈ មានចាំឈ្មោះអីទេអ៊ី?

សារឿនៈ អត់ទេ ខ្ញុំអត់ចាំឈ្មោះផង ។

ប៊ុនថនៈ ចឹងការងារអ៊ីប្រូតហ្នឹងមានតឹងតែងទេ កំណត់ឲ្យធ្វើទេ?

សារឿនៈ តឹងដែលកាលហ្នឹងយ៉ាប់អារឿងកូនចៅគេមិនឲ្យនៅជាមួយ គេបំបែកឲ្យនៅតាមកងតូចៗ
អ៊ី ដកកូនចៅអីប៉ុណ្ណឹងទៅ បាយទឹកអីគេប្រយ័ត្នអត់បានទេ ។

ប៊ុនថនៈ បាទ ។

សារឿនៈ ហូបអត់ហូបឃ្លានទៅ លើកឡើងពីចំណុចហ្នឹងគួរឲ្យអាណោចអាធមដែលហ្នឹង ។

ប៊ុនថនៈ ខ្ញុំចង់ដឹងប្រវត្តិដូចថាអ៊ីមានរឿងអីអីលើកយកមក?

សារឿនៈ លើកពីប្រវត្តិហ្នឹងគួរឲ្យអាណោចអាធមណាស់ គេធ្វើការចុះមកបញ្ឈាំងកុនឲ្យយើងឃើញ

ចឹងៗគួរឲ្យឆ្អែតឆ្អល់គួរយំ ស្រក់ទឹកភ្នែកម្នាក់ៗ កាលចុះមកពីភ្នំពេញដើរធ្វើការ ។

ប៊ុនថន: បាទ ។

សាវឿន: គេបញ្ជាំងកុនឲ្យយើងមើលហ្នឹង ។

ប៊ុនថន: បាទ! អ៊ីំមើលទៅនឹកឃើញរឿងពីដើម?

សាវឿន: មើលទៅឃើញកំសត់ រំដោះមកបានប៉ុណ្ណឹងយើងបានជួបជុំកូនចៅបងប្អូនវិញ ។

ប៊ុនថន: បាទ ។

សាវឿន: ម៉ែឪមកជុំគ្នាវិញ ។

ប៊ុនថន: ចឹងបងប្អូនអ៊ីំកាលហ្នឹងអត់មានជម្លៀសទៅណាឆ្ងាយទេ?

សាវឿន: ដូចថាជម្លៀសចឹងទៅ ទៅមង្គលបូរីទៅស្វាយអីប៉ុណ្ណឹង ។

ប៊ុនថន: អត់មានទៅខេត្តផ្សេងឆ្ងាយៗទេ?

សាវឿន: អត់មានទេ ជម្លៀសភូមិនេះភូមិនោះទៅ ។

ប៊ុនថន: ចឹងកាលអ៊ីំទៅនៅភូមិលាវហ្នឹង ដូចថាលាវហ្នឹងហូបបាយជុំជាមួយខាងខ្មែរហ្នឹង?

សាវឿន: ចាស! ជុំគ្នា ធ្វើការក៏ជុំគ្នាសហករណ៍ក៏ជុំគ្នាអ្នកដឹកនាំមើលខុសត្រូវជុំគ្នាចឹងឯង ។

ប៊ុនថន: ចឹងលាវគេនិយាយភាសាលាវឬភាសាខ្មែរអ៊ីំ?

សាវឿន: គេអត់មាននិយាយលាវទេ និយាយតែខ្មែរដូចយើងចឹង ។

ប៊ុនថន: តែគេចេះនិយាយលាវទេ?

សាវឿន: ចាស! គេចេះនិយាយលាវគេជាសញ្ជាតិលាវណាស់ សាសន៍គេលាវ ។

ប៊ុនថន: បាទ ។

សាវឿន: គេនិយាយហ្នឹងយើងទៅធ្វើការជុំគ្នាអីគេនិយាយខ្មែរដូចតែគ្នា ។

ប៊ុនថន: បាទ ។

សាវឿន: គេអត់មាននិយាយលាវទេ ។

ប៊ុនថន: តែចេះភាសាលាវដែលជនជាតិលាវហ្នឹង?

សាវឿន: គេចេះលាវ ។

ប៊ុនថន: ចឹងគេអត់មាននិយាយទំនាក់ទំនងជាមួយកូនគេចឹង គេមាននិយាយលាវទេ?

សាវឿន: អត់មាននិយាយទេ គេនិយាយគ្នាគេក៏គេនិយាយខ្មែរដែរ កាលពីសម័យហ្នឹង ។

ប៊ុនថន: បាទ ។

សាវឿន: គេនិយាយខ្មែរទាំងអស់ និយាយជាមួយម៉ែឪបងប្អូនកូនចៅគេនិយាយខ្មែរទាំងអស់ ។

ប៊ុនថន: ចឹងកាលរស់នៅអីខុសគ្នាជាមួយខ្មែរយ៉ាងម៉េចទៅអ៊ីំ?

សាវឿនៈ រស់នៅដូចតែយើងដែរ ។

ប៊ុនថនៈ ដូចថាទំលាមទំលាប់ហូបចុកអី?

សាវឿនៈ ហូបចុកអីសម័យហ្នឹងដែលហ៊ានដូចកាលយើងសេរី ចេះតែដូចគ្នាទាំងអស់ ។

ប៊ុនថនៈ ចឹងអ៊ំនៅខាងរោងបាយហ្នឹងគេហូបរួមអីអ៊ំ?

សាវឿនៈ ហូបរួមទៅ ដូចជាខ្ញុំចឹងទៅនៅលាងចានចឹង អ្នកសមរភូមិមុខសមរភូមិក្រោយគេមកហូបទៅ ។

ប៊ុនថនៈ បាទ ។

សាវឿនៈ យើងលានចានផ្កាប់ទុកទៅ បំរើគេ គេនៅយប់ស្នាណាយើងនៅយប់ស្នានោះដែរ ។

ប៊ុនថនៈ បាទ ។

សាវឿនៈ ពួកអ្នកធ្វើគ្នោតធ្វើស្ករអី ឡើងៗយប់បានមកយើងនៅចាំគេចឹងទៅ ។

ប៊ុនថនៈ ចាំរៀបឲ្យគេហូបទៅ?

សាវឿនៈ ចាស!គេហូបរួចបានយើងឡើងដេក ។

ប៊ុនថនៈ ការងារធ្ងន់ទេខាងលាងចានហ្នឹង?

សាវឿនៈ វាមិនធ្ងន់ណាស់ណាទេ តែវានឿយ ។

ប៊ុនថនៈ នឿយយ៉ាងម៉េចអ៊ំ?

សាវឿនៈ វាហត់នឿងទៅណាស់ ដូចថាយើងត្រូវកិនស្រូវយើងត្រូវទុកដាក់អានេះអានោះអីទៅបោសប្រាសបានឈប់ដៃ ។

ប៊ុនថនៈ បាទ ។

សាវឿនៈ សម្អាតកន្លែងគេកន្លែងឃ្លាំង ចានឆ្នាំងយើងដុះមនុស្សរាប់ពាន់រាប់រយមួយសហករណ៍ហ្នឹងរាប់ទៅតិចភូមិណាស់ មិនដឹងជាប៉ុន្មានភូមិនៅជុំគ្នាហូបតែសហករណ៍មួយហ្នឹងទៅ ។

ប៊ុនថនៈ ចឹងហូបហ្នឹងអ្នកនៅក្នុងភូមិហ្នឹងឬមួយប្រជាជននៅកន្លែងផ្សេងទៀត?

សាវឿនៈ កន្លែងផ្សេងខ្លះ អ្នកនៅក្នុងភូមិហ្នឹងខ្លះ ភូមិលាវខ្លះទៅ ភូមិអីលើអីក្រោមខ្លះទៅបញ្ចូលគ្នាទៅ យើងធ្វើស្អុតយើងធ្វើល្អទៅហ្នឹងគេដាក់ឲ្យយើងធ្វើទៅ ពួកអ្នកប្រជាជនភូមិយើងហ្នឹងណាស់ ដូចថាចេះត្រិះរិះគ្នាយល់គ្នាទៅមកចេះតែឲ្យនៅបំរើគ្នាទៅ ។

ប៊ុនថនៈ បាទ ។

សាវឿនៈ គេមានដាក់យើងឲ្យទៅណា ។

ប៊ុនថនៈ បាទ ។

សាវឿនៈ យើងសមូហភាពក្នុងភូមិណាស់ ។

ប៊ុនថន: ស្គាល់ៗ ។

សារឿន: ចាស!អ្នកដែលនៅជាមួយៗមិនស្គាល់ក៏គេមកស្នើអីសុំអីឲ្យទៅឲ្យតែគេចេះលាក់លៀម កុំខាងនិរតីឬយោធាអីឃើញណាស់ ។

ប៊ុនថន: បាទ ។

សារឿន: ខ្លាចគេឃើញគេធ្វើបាបខ្ញុំទៅណាស់ ។

ប៊ុនថន: លាក់លៀមយ៉ាងម៉េចអ៊ី?

សារឿន: ដូចថាគេសុំអំបិលឬគេសុំអីយកទៅស៊ីអីចឹង ។

ប៊ុនថន: អ៊ីជួយឲ្យ?

សារឿន: ចាស!ៗឲ្យតែចេះជួយលាក់ ខ្លាចគ្នាហូបអីវាសាបអីណាស់ កាលហ្នឹងវាតឹងរឹងមិនឲ្យគ្នាស៊ីឆ្ងាញ់ប្រៃអីមិនឲ្យយើងមានអំបិលមានអីនៅតាមផ្ទះ ។

ប៊ុនថន: បាទ ។

សារឿន: មានតែនៅក្នុងសហករណ៍ ។

ប៊ុនថន: ចឹងអ៊ីជួយលាក់អំបិលលាក់ស្ករអីហ្នឹង?

សារឿន: ចាស!ចេះតែឲ្យគេទៅ ឲ្យតែគេចេះលាក់កុំឲ្យគេឆែកឃើញ ។

ប៊ុនថន: ចឹងបើខាងយោធាឆែកឃើញ?

សារឿន: គេកសាងយើងទម្លាក់យើងចោល ផ្លាស់ឲ្យអ្នកថ្មីទៀត ។

ប៊ុនថន: បាទ ។

សារឿន: ដាក់យើងឲ្យទៅធ្វើអីតាពាសចឹងទៅ តែអ្នកដែលនៅក្នុងភូមិហ្នឹងដែលគ្នាហត់នឿយគ្នាខំទៅធ្វើការដូចថាធ្វើចំការស្រែអី ដែលគ្នាហត់នឿយគ្នាស៊ីមិនគ្រប់មិនគ្រាន់ក៏គ្នាគ្មានកំលាំងដែរ ដូចថានៅក្នុងសហករណ៍ហ្នឹងយើងចេះគ្នាស្នើទៅយើងឲ្យគ្នា តិចតួចទៅក៏ចេះលាក់លួចគ្នាបានយកទៅប្រឡាក់ត្រីអីតិចបន្តួចទៅលួចអាំងអីទៅ ។

ប៊ុនថន: បាទ!ចឹងអ៊ីអ្នកមកសុំអ៊ីមានច្រើនគ្នាទេ?

សារឿន: អ្នកណាដែលគេនេះទៅ គេខ្ជិលគេទៅក៏គេមិនសុំទៅអ្នកណាដែលគ្នាខ្វះខាតមានអីហូបទៅដូចថាសល់បាយកកអីទៅក៏ហូបនិងអំបិលហ្នឹងទៅ ។

ប៊ុនថន: បាទ ។

សារឿន: លួចហូបទៅ ។

ប៊ុនថន: ចឹងអ៊ីនៅពេលបាយហ្នឹងរហូតអត់មានផ្លាស់ទៅណាទេ?

សារឿនៈ ខ្ញុំនៅបានមួយឆ្នាំជាងមានសន្តិភាព មុនខ្ញុំទៅធ្វើការដែលកូនយើងមានទម្ងន់ទៅពោះធំអី គេឲ្យយើងទៅធ្វើនេះធ្វើនោះអី ។

ប៊ុនថនៈ ធ្វើអីខ្លះ?

សារឿនៈ ទៅច្រូតទៅស្ទូងទៅដូចថាទៅដកទ្រាលអីធ្វើការទៅយើងពោះធំ ជិតគ្រប់ខែបានគេឲ្យយើងតុបតែង ។

ប៊ុនថនៈ បាទ ។

សារឿនៈ ធ្វើការនៅជិតៗផ្ទះយើងកើតបានចំនួនមួយខែចេះ ចឹងឲ្យយើងចេញលាងចាន ។

ប៊ុនថនៈ បាទ ។

សារឿនៈ គេមិនឲ្យយើងលើកអីធ្ងន់ទេ គេឲ្យយើងលាងចាន ដល់បានពីរខែបីខែបានយើងលើកឆ្នាំង លើកអីបំរើគេ ។

ប៊ុនថនៈ អ៊ឹនិយាយថាក្រោយបែក៧៩ហ្នឹងអ៊ីទៅនៅណាហ្នឹង?

សារឿនៈ នៅភូមិហ្នឹងឯងវិញ ។

ប៊ុនថនៈ នៅភូមិហ្នឹងវិញ?

សារឿនៈ ចាស!ភូមិរហាត់ទឹក ។

ប៊ុនថនៈ ចឹងអត់មានទៅណាទៀតទេ?

សារឿនៈ អត់មានទៅណាទេ ។

ប៊ុនថនៈ ចុះបងប្អូនអ៊ីឪពុកម្ដាយនៅហ្នឹងទេ?

សារឿនៈ នៅដល់ចឹងសន្តិភាពទៅក៏មករកស្រុកមករកស្រែនៅវិញ ។

ប៊ុនថនៈ បាទ!ពេលបែកភ្លាមហ្នឹងអ្នកនៅក្នុងភូមិហ្នឹងមានរត់មកទេ?

សារឿនៈ មាន ខ្លះទៅនៅឆ្ងាយៗទៅ ។

ប៊ុនថនៈ ចឹងមានរត់មកនៅហ្នឹងខ្លះទេ?

សារឿនៈ នៅម៉ាឡៃហ្នឹង ។

ប៊ុនថនៈ បាទ ។

សារឿនៈ មានខ្លះដែរ តែទៅវិញអស់ហើយលាវអីមានមកបងប្អូននៅនេះដែរ ពួកលាវពួកអីណាស់ ។

ប៊ុនថនៈ ចឹងរត់មកដល់ហ្នឹងដែរលាវ?

សារឿនៈ ចាស!រត់ទៅនៅវិញអស់ហើយ ទៅនៅភូមិវិញអស់ ។

ប៊ុនថនៈ ចឹងមានអ្នកខ្លះមករស់នៅហ្នឹងរហូតដល់រាល់ថ្ងៃ?

សារឿនៈ ចាស!ខ្ញុំរកស៊ីនៅហ្នឹងរហូតទៅ ។

ប៊ុនថនៈ មកពីដើមពោធិពីរដើមហ្នឹងឥឡូវមានទេអ៊ំ?

សារឿនៈ មកនៅនេះ ។

ប៊ុនថនៈ បាទ ។

សារឿនៈ អត់មានទេ មានតែខ្ញុំ គេទៅវិញអស់ហើយ ខ្ញុំបងប្អូនកូនក្មួយនៅនេះទៅ ។

ប៊ុនថនៈ គាត់មកនៅហ្នឹងយូរហើយកូនក្មួយ?

សារឿនៈ គេនៅតាំងពីអើយនោះ ។

ប៊ុនថនៈ តាំងពីបែកភូមនោះ?

សារឿនៈ ចាស។!សម័យគេមានដីធ្លីនៅនេះស្រេចទាំងអស់ ភូមិស្រុកគេនៅម៉ាឡៃរហូតមក ។

ប៊ុនថនៈ ចឹងនៅភូមិអ៊ំធ្វើអីពេលបែកហើយ?

សារឿនៈ មានធ្វើអីទេ មានតែធ្វើស្រែហ្នឹងរកត្រី។ ។នៅជិតស្ទឹង គ្រួសារខ្ញុំកាលគាត់នៅរស់រកតែត្រី ។

ប៊ុនថនៈ ចឹងកាលអ៊ំមកនៅម៉ាឡៃហ្នឹងឆ្នាំណា?

សារឿនៈ គិតទៅខ្ញុំមកនៅ៧ឆ្នាំហើយ ។

ប៊ុនថនៈ ២០០៣?

សារឿនៈ ចាស!ខ្ញុំមកនៅ៧ឆ្នាំ ឆ្នាំនេះ ។

ប៊ុនថនៈ ចឹងមកនៅទាំងកូនអីទាំងអស់?

សារឿនៈ កូនដែលបានប្ដីទៅខ្លះគេទៅភ្នំពេញខ្លះគេទៅនៅប៉ោយប៉ែត ដែលគេមានប្ដីមានប្រពន្ធអីណាស់ ។

ប៊ុនថនៈ ចឹងនៅជាមួយអ៊ំប៉ុន្មាននាក់?

សារឿនៈ មកនៅជាមួយខ្ញុំមកនៅស្រុកម៉ាឡៃហ្នឹងមានប្រពន្ធមួយនៅស្រុកម៉ាឡៃនេះ ។

ប៊ុនថនៈ បាទ ។

សារឿនៈ ហើយមានប្ដីមួយ ។

ប៊ុនថនៈ មានប្ដីមួយ?

សារឿនៈ ចាស!នៅជុំ ។

ប៊ុនថនៈ ជុំគ្នា?

សារឿនៈ កូនបីហើយមកនៅនេះដែលបានប្ដី ។

ប៊ុនថនៈ ចឹងអ៊ំនៅសល់កូនប៉ុន្មាននាក់ឥឡូវ?

សាវឿនៈ នៅសល់តែមួយពៅគេ ។

ប៊ុនថនៈ ចឹង៦នាក់ចេញអស់ហើយបែក?

សាវឿនៈ ចាស!ចេញតែ៥ ។

ប៊ុនថនៈ ចឹងចេញ៥នាក់?

សាវឿនៈ ចាស!នៅមានប្ដីមួយនិងក្រមុំមួយនៅជុំ ។

ប៊ុនថនៈ ចឹងមាននៅរៀនទេ កូនអីក្រោយគេ?

សាវឿនៈ កូនពៅឈប់រៀនហើយ នៅជួយលក់ឥវ៉ាន់បងវា ។

ប៊ុនថនៈ លក់ឥវ៉ាន់នៅផ្សារហ្នឹង?

សាវឿនៈ នៅភ្នំពេញនេះមកមិនទាន់ទៅវិញទេ ទៅវិញស្អែកពេលមានបុណ្យទានបានមកម៉ែ ។

ប៊ុនថនៈ បាទ ។

សាវឿនៈ ជួយលក់ឥវ៉ាន់របស់បងបង្កើតនៅភ្នំពេញ ។

ប៊ុនថនៈ លក់អីវិញអ៊ី?

សាវឿនៈ លក់ផ្លែឈើ លក់ណែមអីទៅ ។

ប៊ុនថនៈ នៅណាអ៊ី?

សាវឿនៈ នៅផ្សារដើមគរ ។

ប៊ុនថនៈ ចឹងមានដែលមកលេងអ៊ីទេ?

សាវឿនៈ មកនោះទៅវិញស្អែក ។

ប៊ុនថនៈ អត់ទេ បងនោះ?

សាវឿនៈ បង១មកទើបតែទៅ ។

ប៊ុនថនៈ មកពេលភ្ជុំហ្នឹង?

សាវឿនៈ មកភ្ជុំចូលឆ្នាំ តែខែបុណ្យបានមកម៉ែ ហើយបើម៉ែឈឺអីបានមកម៉ែ ។

ប៊ុនថនៈ នៅប៉ោយប៉ែតមួយ?

សាវឿនៈ ចាស ។

ប៊ុនថនៈ ចឹងបាត់ដីបង?

សាវឿនៈ បាត់ដីបងមួយបានប្ដីស្រី ។

ប៊ុនថនៈ ចឹងអ៊ីមានមូលហេតុអីបានជាអ៊ីមកនៅហ្នឹង?

សាវឿនៈ ខ្ញុំមករកស៊ីហ្នឹង តាំងពីខ្មោចប្ដីខ្ញុំគាត់ខូចខ្ញុំរកស៊ីទៅមកទៅឃើញរកស៊ីនៅហ្នឹងជួបបងជួបប្អូនទៅនៅហ្នឹងបណ្ដោយទៅ ។

ប៊ុនថន: បាទ ។

សារឿន: នៅបណ្ដោយខ្ញុំផ្ទាស់ឈ្មោះផ្ទាស់អីពីហ្នឹងមកប្រធានភូមិធ្វើសំបុត្រស្នាមអីទៅអគ្រានុគោលដ្ឋានអត្តសញ្ញាប័ណ្ណនៅទីនេះទៅ ។

ប៊ុនថន: បាទ ។

សារឿន: ជាប់នៅនេះទាំងកូនអីប៉ុន្មាននាក់ទៅ ។

ប៊ុនថន: បាទ ។

សារឿន: កូនស្រុកកូនស្រែនេះទៅ ។

ប៊ុនថន: បាទ!គាត់ស្លាប់ឆ្នាំណាត្រូសារអឺ?

សារឿន: មិនដឹងជាគាត់ស្លាប់ឆ្នាំណាតាំងពីកូនខ្ញុំអាយុ៦ឆ្នាំ ឥឡូវកូនខ្ញុំ២១ហើយ ។

ប៊ុនថន: ស្លាប់តាំងពី៩០ជាងអឺ?

សារឿន: ចាស ។

ប៊ុនថន: ចឹងកាលអឺផ្ទាស់មកនៅហ្នឹងដំបូងអឺរកអីវិញ?

សារឿន: ខ្ញុំមកខ្ញុំស៊ីឈ្នួលគេ ស៊ីឈ្នួលកាប់អំពៅសណ្ដែកទៅ ស៊ីឈ្នួលដល់សព្វថ្ងៃហ្នឹងឯងស៊ីឈ្នួលគេទាំងម៉ែទាំងកូនទៅ ។

ប៊ុនថន: ស៊ីឈ្នួលខាងខ្មែរខាងថៃ?

សារឿន: ខាងថៃក៏យើងមកវិញល្ងាចហើយខ្មែរកាលហ្នឹង ។

ប៊ុនថន: ចឹងអឺមកដំបូងធ្វើការរកស៊ីអីស្រួល?

សារឿន: អត់ទេ ខ្ញុំដើរស៊ីតែឈ្នួលគេហ្នឹងឯង កាប់ពោតទៅ ធ្វើស្មៅទៅ ។

ប៊ុនថន: និយាយថាមកដំបូង?

សារឿន: ចាស!ដំបូងហ្នឹងឯង ។

ប៊ុនថន: ឆ្នាំ៩៣ហ្នឹង និយាយថាអឺនៅនេះស្រួលរកស៊ីឬមួយពិបាក?

សារឿន: ស្រួលមិនស្រួលបើយើងស៊ីឈ្នួលគេ មានមុនការស៊ីឈ្នួលគេមួយមុខតែប៉ុណ្ណឹងឯង ។

ប៊ុនថន: បាទ ។

សារឿន: យើងអត់មានដីអត់មានអីមួយដុំ ។

ប៊ុនថន: ចឹងកាល៩៣នៅនេះមានផ្លូវហើយនៅ?

សារឿន: មានហើយ ។

ប៊ុនថន: មានអស់ហើយ?

សារឿន: ចាស!ដូចជានៅចេះអីហ្នឹងគេនៅតាំងពីអើយមក ។

ប៊ុនថន៖ ខាងណាផ្ទះអ៊ំអីហ្នឹង?

សារឿន៖ ចាស ។

ប៊ុនថន៖ ចឹងកាលថ្ងៃមុនថាបានទៅមើលគេបញ្ចាំងកូនឯកសារដែរ?

សារឿន៖ ចាស! មើល ។

ប៊ុនថន៖ អ៊ំទៅចូលរួមដែរ?

សារឿន៖ ចូល ។

ប៊ុនថន៖ ថ្ងៃហ្នឹងខ្ញុំមកដែរ ។

សារឿន៖ ចឹងមកនៅវត្ត ។

ប៊ុនថន៖ បាទ ។

សារឿន៖ កាលហ្នឹងនៅវត្តហ្នឹងឯងខ្ញុំទៅ ខ្ញុំតែពេលប្រជុំប្រធានភូមិមកហៅទៅ ។

ប៊ុនថន៖ បាទ ។

សារឿន៖ ត្រូវការទៅណាប្រធានភូមិមកហៅទៅ ។

ប៊ុនថន៖ ចឹងអ៊ំមើលរឿងហ្នឹងយ៉ាងម៉េចដែរ?

សារឿន៖ ខ្ញុំមើលវល់តែយំដែរ នឹកស្រណោះខ្លួននឹកស្រណោះបងប្អូនកូនចៅហត់នឿយពិបាក ។

ប៊ុនថន៖ បាទ ។

សារឿន៖ បែកកូនបែកចៅអីទៅណាស់ ។

ប៊ុនថន៖ មើលនៅហ្នឹងមានកាត់ទោសកាត់អីដែរ?

សារឿន៖ មាន ។

ប៊ុនថន៖ តែអ៊ំមានបានមើលតាមទូរទស្សន៍អីទេ?

សារឿន៖ មើលទូរទស្សន៍ខ្ញុំមើល មើលកុនអីហ្នឹងចូលចិត្តមើល ។

ប៊ុនថន៖ ចឹងអ៊ំមានដែលឮតុលាការកាត់ទោសអីទេ?

សារឿន៖ ឮតែគេនិយាយ ។

ប៊ុនថន៖ ចឹងអ៊ំមានដែលឮគេផ្សាយតាមវិទ្យុអីទេ?

សារឿន៖ ចាស ។

ប៊ុនថន៖ អ៊ំយល់យ៉ាងម៉េចដែលរឿងកាត់ទោសហ្នឹងអ៊ំ?

សារឿន៖ បានមកស្រួលប៉ុណ្ណឹងកូនអើយបុណ្យគុណណាស់ ត្រេកអរណាស់ ។

ប៊ុនថន៖ បាទ ។

សារឿន៖ បានប៉ុណ្ណឹងបានរស់អាយុជីវិតមកប៉ុននេះបានជុំកូនជុំចៅវិញអរណាស់នឹកកាលយើងឈឺ

រប់ពីមុនៗមកធ្វើម៉េចវាផុតទៅហើយ ។

ប៊ុនថន: ចឹងអ៊ឹធ្លាប់រស់នៅកាលសម័យនោះដូចថាកាលកាត់ទោសអីអ៊ឹយល់យ៉ាងម៉េចដែរ អ៊ឹយល់ថាត្រឹមត្រូវឬមិនត្រូវទេ?

សារឿន: សម័យហ្នឹងត្រឹមត្រូវហើយ ។

ប៊ុនថន: ត្រឹមត្រូវយ៉ាងម៉េចមីង?

សារឿន: ជួយរំដោះឲ្យបានផុតមកស្រួល ។

ប៊ុនថន: អ៊ឹចង់និយាយថា កាលហ្នឹងអ៊ឹមានស្គាល់មេដឹកនាំប្រទេសអីទេ?

សារឿន: មិនដែលស្គាល់ទេ ។

ប៊ុនថន: មិនដែលស្គាល់ទេ?

សារឿន: អត់ទេ ឮតែគេនិយាយ មើលកាលមកបញ្ចាំងកុននៅវត្តហ្នឹងពីណាគេដឹងគេឡើងនិយាយកោកៗ ។

ប៊ុនថន: បាទ ។

សារឿន: គេដឹងប្រវត្តិដឹងអី ខ្ញុំមិនបានដឹងអីបន្តិចទេកូនអើយ ។

ប៊ុនថន: បាទ!គាត់រស់នៅហ្នឹងតាំងពីមុនមកគាត់ដឹង?

សារឿន: ចាស! គេធ្លាប់រស់នៅកន្លែងគេ ព្រោះគេជាពូជអ្នករំដោះដែរ ។

ប៊ុនថន: ខាងរំដោះដែរ?

សារឿន: ចាស!គេឡើងនិយាយទៅ ។

ប៊ុនថន: ចឹងអ៊ឹខាងក្នុងនោះ?

សារឿន: ចាស!តែឆ្លងកាត់ការពិបាកដូចតែគ្នាទេ ។

ប៊ុនថន: កាលអ៊ឹមកដល់ដំបូងមាននៅសល់ព្រៃអីទេ មកដល់ដំបូងកាល៩៣?

សារឿន: មានតែកូន ។

ប៊ុនថន: ច្រើនទេ?

សារឿន: ច្រើន មានព្រៃគេដោះមិនដោះអី ។

ប៊ុនថន: និយាយថាព្រៃដើមឈើធំៗនៅមានទេ នៅម៉ាឡៃហ្នឹង?

សារឿន: នៅម៉ាឡៃអត់មានទេ មានតែនៅលើភ្នំអីចឹង ។

ប៊ុនថន: នៅមាន?

សារឿន: ចាស!ឥឡូវស្រឡះអស់ហើយ គេកាប់គេអីអស់ហើយ ។

ប៊ុនថន: កាលអ៊ឹចូលមកដល់ដំបូងហ្នឹងផ្លូវអីពិបាកទេ?

សារឿនៈ ពិបាកហ្នឹងឯង ។

ប៊ុនថនៈ ចឹងឆ្នាំ៩៣នៅពិបាកដែរ?

សារឿនៈ ចាស!ពិបាកដែរ ។

ប៊ុនថនៈ អត់ទាន់មានដូចដូវរាល់ថ្ងៃទេ?

សារឿនៈ ចាស ។

ប៊ុនថនៈ ពិបាកជាងហ្នឹង?

សារឿនៈ ចាស!ពិបាកមិនទាន់មានស្រួលដូចចេះទេ នៅស្តុកដែលតាមហ្នឹងតាមភូមិតាមអីនៅស្តុក ។

ប៊ុនថនៈ នៅមានព្រៃដុះដែរ?

សារឿនៈ ចាស!នៅមានព្រៃដុះ ខ្ញុំចូលដំបូងខ្ញុំជួលដីនេះនៅផ្ទះនេះ ខ្ញុំជួលកន្លែងហ្នឹងនៅបីឆ្នាំ បីឆ្នាំខ្ញុំទើបតែធ្វើផ្ទះនៅមិនទាន់បានមួយឆ្នាំទេ ធ្វើផ្ទះខ្លួនឯង ។

ប៊ុនថនៈ បាទ ។

សារឿនៈ កូនចៅទៅស៊ីឈ្នួលគេត្រឹកៗទៅទិញសរសរអីធ្វើនៅទៅក្អួយឲ្យដីនៅ នៅលើដីគេទេអត់មានដីខ្លួនឯងទេ ។

ប៊ុនថនៈ ចឹងរាល់ថ្ងៃនៅលើដីក្អួយ?

សារឿនៈ ចាស!នៅលើដីគេតែផ្ទះយើង ខ្ញុំមកនៅ៧ឆ្នាំហ្នឹងហើយ ខ្ញុំជួលគេអស់៦ឆ្នាំជួលផ្ទះគេនៅ ។

ប៊ុនថនៈ ជួលផ្ទះគេនៅ?

សារឿនៈ ចាស!អស់៦ឆ្នាំ ធ្វើខ្លួនឯងមិនទាន់បានមួយឆ្នាំផង ។

ប៊ុនថនៈ ចឹងយ៉ាងម៉េចបានអីចេញពីផ្ទះហ្នឹងអី?

សារឿនៈ គេមិនឲ្យចេញទេ គេធ្វើឲ្យខ្ញុំនៅទៀតតែយើងធ្វើរកបានខ្លួនយើងទៅក្អួយឲ្យដីអីទៅយើងធ្វើនៅខ្លួនឯងទៅ បើជួលគេណាថ្លៃផ្ទះផងថ្លៃហូបផងវាកាន់តែយ៉ាប់ទៅ ។

ប៊ុនថនៈ អូរ!មកនៅនេះជួលនៅ?

សារឿនៈ ចាស!មួយខែ៣០០ ។

ប៊ុនថនៈ ៣០០ស្មើ៣០០០រៀល?

សារឿនៈ ចាស!មួយឆ្នាំ៣០០០បាត ខ្ញុំជួលគេអស់៦ឆ្នាំ ។

ប៊ុនថនៈ បាទ ។

សារឿនៈ ដល់ក្អួយគេឲ្យដីនៅបានទិញសរសរឬស្សីអីធ្វើផ្ទះនៅខ្លួនឯង ។

ប៊ុនថនៈ បាទ ។

សារឿនៈ	កូនគេឲ្យមកខ្លះមក ។

ប៊ុនថនៈ	ចឹងអ៊ីចូលមកកាល៩៣ហ្នឹងមាននៅព្រៃនៅអីទេ?

សារឿនៈ	មានព្រៃច្រើនដែរ ។

ប៊ុនថនៈ	មានមីនមានអីដែរ?

សារឿនៈ	ចាស!តែមានពួកស៊ីម៉ាក់គេដោះអីចេញទៅ ។

ប៊ុនថនៈ	ទើបតែចូលដោះស៊ីម៉ាក់ឬដោះនៅឆ្នាំណា?

សារឿនៈ	មកដោះយូរដែរ ។

ប៊ុនថនៈ	និយាយថាខាងស៊ីម៉ាក់ចូលមកដោះនៅម៉ាឡៃហ្នឹងចូលមកយូរហើយ?

សារឿនៈ	ចូលយូរគ្រាន់ហើយ គេនៅតែដើរមើល ។

ប៊ុនថនៈ	ចឹងអ៊ីនៅហ្នឹងមានខ្លាចមីនទេ?

សារឿនៈ	ចាស!ខ្ញុំមិនសូវហ៊ានដើរផ្ដេះផ្ដាស់ដែរ មិនទុកចិត្តដែលឆ្លងទៅចេះ ។

ប៊ុនថនៈ	ឆ្លងទៅខាងនោះ?

សារឿនៈ	ឆ្លងទៅតាមមាត់អូរយើង ចេះតែខ្លាចដែរ ។

ប៊ុនថនៈ	មាត់អូរតាមព្រំនេះ?

សារឿនៈ	ចាស!ខ្លាចតែនៅមាន បើក្មួយខ្ញុំនៅក្នុងនោះផ្ទុះតែបន្តិចដងនៅរាប់ឆ្នាំ ។

ប៊ុនថនៈ	ផ្ទុះនៅផ្ទុះ?

សារឿនៈ	ចាស!ដើរទៅជីកអន្ទូងអីនៅមានលាក់ៗខ្លះចឹងឯងឥឡូវអស់ហើយ អត់មានទេឥឡូវ ។

ប៊ុនថនៈ	ផ្ទុះមីនមានគ្រោះថ្នាក់មានអីទេ?

សារឿនៈ	មានកំបុតជើង ។

ប៊ុនថនៈ	កំបុតជើង?

សារឿនៈ	ចាស!ត្រឹមកំបុតជើង ។

ប៊ុនថនៈ	នៅផ្ទុះហ្នឹងតែម្ដង?

សារឿនៈ	នៅផ្ទុះតែឥឡូវអស់ហើយ ស៊ីម៉ាក់គេមកឆ្កុះអស់ ។

ប៊ុនថនៈ	ចឹងអ៊ីខ្ញុំចង់សួរសំនួរមួយទៀតដូចជាអ៊ីនៅជំនាន់ខ្មែរក្រហមហ្នឹងអ៊ីមានជួយគេច្រើនទេ
មានបានជួយដូចជាឲ្យអំបិលអីនោះ?

សារឿនៈ	ចាស ។

ប៊ុនថនៈ	ចឹងក្រៅពីហ្នឹងអ៊ីមានជួយផ្សេងៗ?

សារឿនៈ អត់មានហ៊ានយកអីទៀតទេ ខ្លាចដែរ គេចាំមើលគេតាមដានយើងដែរ ។

ប៊ុនថនៈ បាទ ។

សារឿនៈ មានលាក់ៗបន្តិចបន្តួចឲ្យគ្នាឯងហូបអំបិលក្រៅពីហ្នឹងមិនហ៊ានតែធំដុំខ្ញុំមិនហ៊ានទេ ខ្ញុំខ្លាចគេវ៉ៃព្រោះខ្ញុំឃើញហ្នឹងភ្នែកហើយ វ៉ៃគីសក្លួសងាប់ ។

ប៊ុនថនៈ បាទ ។

សារឿនៈ នៅមុខៗ ។

ប៊ុនថនៈ ចឹងអ៊ឹមានអីបន្ថែមទៀតទេអ៊ឹ ដែលចង់រៀបរាប់អីទៀត?

សារឿនៈ មានអីចប់ត្រឹមហ្នឹងហើយ ។

ប៊ុនថនៈ ចឹងអ៊ឹមាននៅសល់រូបថតចាស់ៗទេ នៅសល់ពីដើមៗមក?

សារឿនៈ រូបថតខ្ញុំ?

ប៊ុនថនៈ បាទ!តាំងពីដើមមកអ៊ឹការអីហ្នឹង?

សារឿនៈ អ៊ី!នៅកូននោះ ។

ប៊ុនថនៈ នៅផ្ទះអត់មាននៅ?

សារឿនៈ មានតែរូបបោះឆ្នោតអីហ្នឹងឯង ។

ប៊ុនថនៈ រូបពីដើម?

សារឿនៈ ចាស!នៅកូនដាក់អីស្រុកអីផ្ទះអីកូនចៅអីនោះមើលខ្ញុំមកនៅនេះមិនដែលថតអីផង ។

ប៊ុនថនៈ បាទ ។

សារឿនៈ ខ្ញុំមានតែរូបថតក្នុងអត្តសញ្ញាណប័ណ្ណនិងអត្រានុកោលដ្ឋាននិងកាតបោះឆ្នោត ។

ប៊ុនថនៈ បាទ ។

សារឿនៈ នោះយកមកហើយយកទៅមិញ ។

ប៊ុនថនៈ ចឹងខ្ញុំអរគុណអ៊ឹច្រើនហើយ ។

សារឿនៈ ចាស ។

**«ចប់»**